ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សមិទ្ធិផល
# ការអនុវត្តគោលនយោបាយស្តីពីការអប់រំ
# វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម
# និងគណិតវិទ្យា (ស្ទែម)




ខែមីនា ឆ្នាំ២០១៨

# អារម្ភកថា

សព្វថ្ងៃនេះ យើងកំពុងស្ថិតនៅក្នុងយុគសម័យទូរស័ព្ទឆ្លាតវៃ បន្ទប់រៀនឆ្លាតវៃ បច្ចេកវិទ្យាមនុស្សយន្ត ។ល។ ការរីកចម្រើនយ៉ាងលឿនរហ័ស ក្នុងផ្នែកបច្ចេកវិទ្យា នវានុវត្តន៍ និងការបង្កើតថ្មី ជាមូលដ្ឋានគ្រឹះនៃបដិវត្តន៍ឧស្សាហកម្ម ៤.០។ ដូច្នេះហើយ ទើបមានតម្រូវការការអប់រំជំនាន់ទី ៤.០ កើតឡើងដែលនឹងជួយរៀបចំសិស្ស ឱ្យយល់ដឹងអំពីការផ្លាស់ប្តូរ ក្នុងបរិបទពិភពលោក បញ្ហាប្រឈម និងបទពិសោធន៍ នៃទស្សនៈវិស័យនៃការប្រែប្រួល និងរកវិធី/ មធ្យោបាយដ៏ត្រឹមត្រូវដើម្បីគ្រប់គ្រង និងដោះស្រាយ។ នាពេលអនាគតវិធានគរុកោសល្យសម្រាប់បង្រៀន និងខ្លឹមសារនៃការអប់រំ ចាំបាច់ត្រូវរៀបចំកែលម្អឡើងវិញ។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពសិស្ស និស្សិត និងអភិវឌ្ឍធនធានមនុស្សដែលមានសមត្ថភាព និងការទទួលខុសត្រូវ ក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ប្រកបដោយបរិយាបន្ន និងចីរភាព។

ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងបង្កើត និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពជាយុទ្ធសាស្ត្រ ទាក់ទងនឹងការពង្រឹង និងការបញ្ចូលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទៅក្នុងប្រព័ន្ធអប់រំកម្ពុជា។ តាមរយៈការបញ្ចូលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទៅក្នុងប្រព័ន្ធអប់រំនេះ យើងមានគោលដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការងារអប់រំ យុវជន និងកីឡា តាមរយៈការបញ្ជ្រាប និងការប្រើប្រាស់ធនធានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានបច្ចុប្បន្ន និងអនាគត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សហគមន៍ គ្រួសារ បុគ្គល និងគ្រឹះស្ថានសិក្សា ដែលពាក់ព័ន្ធនានានឹងចូលរួមចំណែកគាំទ្រ តាមបែប ឬមធ្យោបាយណាមួយ ដើម្បីសម្រេចឱ្យបានជោគជ័យនូវគោលបំណង និងគោលដៅនៃការប្តេជ្ញាចិត្តនេះ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

## ១. សេចក្តីផ្តើម

### ១.១ គោលដៅនៃការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)របស់ក្រសួងអប់រំ យុវជន និងកីឡា

- បង្កើតលក្ខខណ្ឌនិងបរិស្ថានសមស្របសម្រាប់អភិវឌ្ឍសមត្ថភាពរបស់សិស្ស និស្សិតក្នុងការសិក្សា និងស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
- ផ្តល់នូវក្របខ័ណ្ឌការងារសម្រាប់ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) នៅគ្រប់កម្រិតសិក្សា
- ជំរុញការសិក្សាស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) និងផ្សារភ្ជាប់ការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ទៅក្នុងជីវភាពរស់នៅ និងការអប់រំបំណិនជីវិត
- អភិវឌ្ឍសមត្ថភាពគ្រូ និងអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
- បង្កើនការចូលរួម និងបង្កើនប្រសិទ្ធភាពក្នុងការធ្វើសមាហរណកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដោយមានការចូលរួមពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ។

### ១.២ សេចក្តីសង្ខេបយុទ្ធសាស្ត្រ និងនវានុវត្តន៍ឆ្ពោះទៅរកការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)

- អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ
- អភិវឌ្ឍគ្រឹះស្ថានសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
- ការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)

## ២. សមិទ្ធិផលក្នុងឆ្នាំ២០១៧

### ២.១ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

- បានដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)
- បានដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី
- ការរៀបចំផែនការសកម្មភាពគោលនយោបាយស្តីពីការអប់រំបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ២០១៨-២០២២

### ២.២ ការអភិវឌ្ឍកម្មវិធីសិក្សាស្ទែម

កំណត់ហេតុបណ្តាញធនធានអប់រំ (OER: Open Educational Resources) របស់ក្រសួងអប់រំ យុវជន និងកីឡា គេហទំព័រគ្រូ/មជ្ឈមណ្ឌលធនធានអប់រំអេឡិកត្រូនិក (Krou/Teacher Website) និងទំព័របណ្តាញសង្គមហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា "MoEYS Cambodia" ជួយឱ្យក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងផ្សព្វផ្សាយខ្លឹមសារ ព័ត៌មាន និងឯកសារក្នុងទម្រង់ឌីជីថល/អេឡិកត្រូនិកជូនដល់សិស្ស និស្សិត គ្រូ សាស្ត្រាចារ្យ និងសាធារណជន។

កម្មវិធីតេស្តលំហាត់/សំណួរជីវវិទ្យាថ្នាក់ទី១២ សម្រាប់ដំណើរការតាមទូរស័ព្ទ ត្រូវបានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានបើកទូលាយ ដើម្បីជួយសិស្សឱ្យអាចសិក្សា/រៀនត្រៀមបានយ៉ាងជោគជ័យសម្រាប់ប្រឡងបញ្ចប់មធ្យមសិក្សាចំណេះទូទៅថ្នាក់ជាតិ។

កម្មវិធីសិក្សាលម្អិតបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ថ្នាក់ទី១១ និង ថ្នាក់ទី១២ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្តល់ឱ្យសិស្សនូវជំនាញបច្ចេកទេស ជំនាញគមនាគមន៍/ទំនាក់ទំនង និងចំណេះដឹងច្បាស់លាស់ទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យានៅកន្លែងធ្វើការ។ កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២ផ្តល់ឱ្យសិស្សនូវចក្ខុវិស័យច្បាស់លាស់អំពីគន្លងការងារក្នុងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទាក់ទងនឹងចំណេះដឹង និងព័ត៌មានគ្រប់ជ្រុងជ្រោយដើម្បីធ្វើសេចក្តីសម្រេចចិត្តប្រកបដោយចំណេះដឹងទូលំទូលាយ ក្នុងការជ្រើសរើសគន្លងការងាររបស់ខ្លួន ក្នុងពេលអនាគត។

កម្មវិធីអេឡិកត្រូនិកសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធីសាលាកុមារមេត្រី នៅកម្ពុជា ត្រូវបានបង្កើតឡើង ដោយប្រើថាបឡិត(tablet) ក្នុងការប្រមូលទិន្នន័យចាំបាច់។

កម្មវិធីដំណើរការតាមទូរស័ព្ទ ដែលហៅថា "តេស្ត (TEST)" សម្រាប់សិស្សថ្នាក់ទី១ និងសិស្សថ្នាក់ទី២ ដែលអាចវាយតម្លៃសមត្ថភាពអំណានរបស់សិស្ស ត្រូវបានបង្កើតឡើង។ កម្មវិធីតេស្ត (TEST) នេះត្រូវបានបង្កើនរហូតដល់៨៧ សាលារៀន និងមានអ្នកទទួលផល/អ្នកយកទៅប្រើប្រាស់កើនឡើងរហូតដល់ចំនួន ១០.០០០នាក់។

ប្រព័ន្ធគ្រប់គ្រងសាលារៀន (SMAS: School Management System)ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់ការគ្រប់គ្រងរដ្ឋបាល ការពិនិត្យតាមដានថ្នាក់រៀន ការពិនិត្យតាមដានការបង្រៀន-ចំណាត់ថ្នាក់ការសិក្សា ការគ្រប់គ្រងពិន្ទុសិស្ស និងការលើកកម្ពស់ទំនាក់ទំនងដ៏មានប្រសិទ្ធភាពរវាងសាលារៀន គ្រូ ឪពុកម្តាយសិស្ស/អាណាព្យាបាលសិស្ស និងសិស្ស តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាមូលដ្ឋាន។

ការធ្វើតេស្តតាមគេហទំព័រ "ប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System) "(bacii.moeys.gov.kh) ដើម្បីឱ្យសិស្សអាចអនុវត្តសំណួរនិងលំហាត់គន្លឹះៗ ក្នុងមុខវិជ្ជាគណិតវិទ្យា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា និងប្រវត្តិវិទ្យា។ ប្រព័ន្ធនេះនឹងពង្រឹងសមត្ថភាពសិស្សសម្រាប់ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ របស់សាធារណរដ្ឋកូរ៉េ តាមរយៈអង្គភាពសេវាកម្មព័ត៌មានស្រាវជ្រាវ និងអប់រំកូរ៉េ (KERIS: Korea Education & Research Information Service) ផ្ទាំង/កម្មវិធី /ប្រព័ន្ធកុំព្យូទ័រការសិក្សាតាមអេឡិកត្រូនិក (e-learning) ដំបូងបំផុតនៅកម្ពុជា ត្រូវបានបង្កើតឡើង ដែលក្នុង នោះមានមាតិកា ខ្លឹមសារ និងឯកសារអប់រំសំខាន់ៗដ៏ចាំបាច់ទាំងអស់ អាចត្រូវបានដាក់ឱ្យប្រើប្រាស់តាមបែបអន្តរសកម្មភាព ដើម្បីជំរុញ និងលើកកម្ពស់បរិយាកាសសិក្សាពេញមួយជីវិត។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានគ្រប់គ្រងខាងកើត-ខាងលិច(EWMI: East-West Management Institute)ការរៀបចំផែនទី (ទីតាំងភូមិសាស្ត្រ ដោយមានកូអរដោនេនៃប្រព័ន្ធកំណត់ទីតាំងសាកល (GPS)) របស់សាលារៀនទាំងអស់នៅកម្ពុជាត្រូវបានបង្កើតឡើងព្រមជាមួយនឹងការចេញផ្សាយព័ត៌មានពាក់ព័ន្ធផ្ទាល់តាមបណ្តាញអ៊ីនធឺណិត ការបង្កើតនិងអភិវឌ្ឍឧបករណ៍និងលំហាត់ ដែលបង្រៀនសិស្សានុសិស្សនៅតាមអាយុផ្សេងៗ ព្រមទាំងរបៀបអាន និងបង្កើតផែនទី។

ក្រសួងបានចូលរួមក្នុងការដឹកនាំបច្ចេកទេសដើម្បីបង្កើតប្រព័ន្ធធីអិនធី (TnT System)។ ប្រព័ន្ធធីអិនធី (TnT System) ត្រូវបានប្រើប្រាស់ដើម្បីជួយក្នុងការប្រមូលទិន្នន័យការរៀបចំគម្រោងថវិកាសៀវភៅសិក្សាគោល

និងតាមដានការចែកផ្តល់ និងប្រគល់សៀវភៅសិក្សាគោល។ គម្រោង TnT នឹងត្រូវសាកល្បងជាដំបូងក្នុងខែឧសភា ឆ្នាំ២០១៨ នៅសាលារៀនចំនួន ៤០០ នៅក្នុងខេត្តដែលត្រូវបានជ្រើសរើសចំនួន២។

## ២.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្នែម

### ២.៣.១ សាលាធនធានមធ្យមសិក្សា

សាលាធនធានមធ្យមសិក្សា ត្រូវបានសម្រាំងជ្រើសរើសជាគ្រឹះស្ថានមធ្យមសិក្សាឈានមុខក្នុងគ្រប់ទិដ្ឋភាពទាំងអស់ដូចជា៖ ការអនុវត្តកម្មវិធីសិក្សា លទ្ធផលនៃការសិក្សា ការចែករំលែកបទពិសោធន៍ (ការបង្រៀន ការរៀន និងការគ្រប់គ្រង ។ល។) ផែនការអភិវឌ្ឍន៍សាលារៀន និងសមត្ថភាពគ្រូ។ នៅសាលាធនធានមធ្យមសិក្សា មានអគារធនធាន ដោយរួមមានអគារសាលារៀន បន្ទប់ប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ព្រមទាំងបណ្តាញទឹក និងអគ្គិសនី។សព្វថ្ងៃនេះមានសាលាធនធានមធ្យមសិក្សាចំនួន៣៦។

### ២.៣.២ សាលារៀនជំនាន់ថ្មី

សាលារៀនជំនាន់ថ្មី នៃវិទ្យាល័យ ព្រះស៊ីសុវត្ថិ ជាសាលារៀនគំរូនៃកំណែទម្រង់វិស័យអប់រំស៊ីជម្រៅដែលបានចាប់ផ្តើមដាក់ឱ្យដំណើរការនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦។ មានបន្ទប់រៀនចំនួន២៤ ដែលត្រូវបែងចែកទៅតាមបន្ទប់មុខវិជ្ជាៈ បន្ទប់រៀនគីមីវិទ្យា បន្ទប់រៀនរូបវិទ្យា បន្ទប់រៀនជីវវិទ្យា បន្ទប់រៀនកុំព្យូទ័រ និងបន្ទប់រៀនគណិតវិទ្យា ដែលមានពីថ្នាក់ទី៧ ដល់ ថ្នាក់ទី១២។

វិទ្យាល័យ ព្រះស៊ីសុវត្ថិ អនុវត្តនូវកម្មវិធីសិក្សាស្នែមថ្មីទាំងស្រុងលើកទីមួយ ដែលទាក់ទាញសិស្សពូកែៗឱ្យចូលរៀន និងផ្លាស់ប្តូរសិស្សដែលមិនចូលចិត្តការសិក្សាវិទ្យាសាស្ត្រ ឱ្យចូលរៀន និងរៀនសូត្រទទួលបានលទ្ធផលល្អ។ បន្ថែមលើការសិក្សាក្នុងថ្នាក់រៀន សិស្សមានសកម្មភាពស្រាវជ្រាវជាច្រើនលើភាពល្អប្រសើរ និងភាពប្រកួតប្រជែង ព្រមទាំងមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ-អន្តរជាតិនានា។

វិទ្យាល័យ ព្រះស៊ីសុវត្ថិបាននិងកំពុងអនុវត្តកម្មវិធីថ្មី ដែលឆ្លើយតបទៅនឹងតម្រូវការនៃសិស្សនៅសតវត្សរ៍ទី២១ និងដែលផ្សារភ្ជាប់ការសិក្សានិងការអនុវត្ត។ សិស្សអាចធ្វើការស្រាវជ្រាវរុករកបន្ថែមផងដែរ ក្រៅពីការស្តាប់គ្រូ ដោយប្រើបច្ចេកវិទ្យាសម្រាប់ស្រាវជ្រាវ និងអនុវត្ត។ បន្ថែមលើនេះ សិស្សក៏បានបង្កើតក្លិបសិក្សាជាច្រើនផងដែរ ដូចជា៖ ក្លិបវិទ្យាសាស្ត្រ ក្លិបវីដេអូ និងក្លិបសារព័ត៌មាន...។

វិទ្យាល័យនេះ ក៏បានបង្កើតក្របខ័ណ្ឌស្រាវជ្រាវវិទ្យាសាស្ត្រកម្រិតខ្ពស់ នៅកម្រិតមធ្យមសិក្សាទុតិយភូមិផងដែរ ដែលអាចជួយសិស្សឱ្យមានសមត្ថភាពប្រកួតប្រជែងជាមួយសិស្សដទៃៗទៀត ក្នុងប្រទេស និងអន្តរជាតិ។

វិទ្យាល័យនេះ មានគម្រោងអភិវឌ្ឍន៍ស្នែមមួយចំនួន ដោយរួមមាន៖ ការជំរុញការស្រាវជ្រាវរបស់គ្រូ និងសិស្ស លើមុខវិជ្ជាស្នែម, ការបង្កើតក្លិបស្រាវជ្រាវ និងបង្កើតថ្មី សម្រាប់សិស្ស, ការកែទម្រង់កម្មវិធីសិក្សាស្នែម, ការបង្កើតវប្បធម៌ស្រាវជ្រាវ និងការចេញផ្សាយលទ្ធផល/ស្នាដៃស្នែមរបស់សិស្ស, ព្រមទាំងការធ្វើទំនើបកម្មបន្ទប់/ ទីពិសោធន៍ និងបង្កើតបន្ទប់/ទីពិសោធន៍ថ្មី ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារការងារ។

ម្យ៉ាងវិញទៀត នៅកម្រិតបឋមសិក្សា ក្រសួងបានរៀបចំបង្កើតសាលារៀនជំនាន់ថ្មីចំនួន៤៖ (១) សាលាបឋមសិក្សា ហ៊ុន សែន អនុវត្ត ស្ថិតនៅក្នុងក្រុងកំពង់ចាម ខេត្តកំពង់ចាម, (២) សាលាបឋមសិក្សាអង្គរបាន ស្ថិតនៅក្នុង ស្រុកកងមាស ខេត្តកំពង់ចាម, (៣) សាលាបឋមសិក្សា ស្វាយប្រហូត ស្ថិតនៅក្នុង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង, និង (៤) សាលាបឋមសិក្សា សម្តេចព្រះរាជអគ្គមហេសី នរោត្តមមុនីនាថសីហនុស្ថិតនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

នៅកម្រិតមធ្យមសិក្សា ក្រសួងបានរៀបចំបង្កើតសាលារៀនជំនាន់ថ្មីចំនួន៥៖ (១) វិទ្យាល័យ ព្រះស៊ីសុវត្ថិ នៃរាជធានីភ្នំពេញ, (២) វិទ្យាល័យ ព្រែកលៀប នៃរាជធានីភ្នំពេញ, (៣) វិទ្យាល័យ ហ៊ុន សែន កំពង់ចាមស្ថិតនៅក្នុងក្រុងកំពង់ចាម ខេត្តកំពង់ចាម, (៤) វិទ្យាល័យ ជា ស៊ីម ព្រែកអញ្ចាញ ស្ថិតនៅក្នុងស្រុកមុខកំពូល ខេត្តកណ្តាល, និង(៥) អនុវិទ្យាល័យ គោកព្រីង ស្ថិតនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។















## ២.៣.៣ គ្រឹះស្ថានឧត្តមសិក្សា

### *សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.)*

មាននិស្សិតប្រហែល ៥០% កំពុងសិក្សាមុខវិជ្ជាស្ទែម។ សាកលវិទ្យាល័យកំពុងដំណើរការបណ្តុះបណ្តាល កម្មវិធីថ្នាក់បរិញ្ញាបត្រលើមុខជំនាញសិក្សាដែលទាក់ទងនឹងស្ទែម ចំនួន១០៖ ជីវវិទ្យា, គីមីវិទ្យា, វិទ្យាសាស្ត្រ បរិស្ថាន, វិទ្យាសាស្ត្រកុំព្យូទ័រ, គណិតវិទ្យា, រូបវិទ្យា, វិស្វកម្ម, បច្ចេកវិទ្យាព័ត៌មាន, អេឡិកត្រូនិក និងទូរគមនា គមន៍, និងការគ្រប់គ្រងធនធានធម្មជាតិ។ សាកលវិទ្យាល័យ កំពុងបណ្តុះបណ្តាលកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ ខ្ពស់ លើមុខជំនាញ៖ ជីវ-រូបវិទ្យា, គណិតវិទ្យា, រូបវិទ្យា, វិស្វកម្ម, បច្ចេកវិទ្យាព័ត៌មាន, និងការប្រែប្រួលអាកាសធាតុ។

បន្ទប់/ទីពិសោធន៍មួយចំនួន មានដូចជា៖ បន្ទប់/ ទីពិសោធន៍សម្រាប់ប្រព័ន្ធបរិស្ថាន/ អេកូឡូស៊ី, សារធាតុ

ជីវ-គីមី,ជីវឧស្ម័ន,អតិសុខុមកាយ, វិភាគកុំព្យូទ័រ, រ៉ូបូត, វិភាគគុណភាពទឹក និងការបំពុលខ្យល់,ប្រព័ន្ធព័ត៌មានវិទ្យា, ភូគព្ភសាស្ត្រ, គីមីវិទ្យា,សារធាតុគីមី, រូបវិទ្យាទូទៅ, រូបវិទ្យា, រូបវិទ្យាអនុវត្តន៍, ថាមពលកកើតឡើងវិញ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចូលរួមយ៉ាងសកម្មក្នុងការពង្រឹងសមត្ថភាពសិស្សពូកែ/ឆ្នើម គណិតវិទ្យា និងរូបវិទ្យា (ថ្នាក់ទី១០-ថ្នាក់ទី១២) ដើម្បីចូលរួមប្រកួតប្រជែងអូឡាំព្យាដថ្នាក់តំបន់ និងអន្តរជាតិ។

ក្នុងពេលអនាគត សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នឹងអនុវត្តគម្រោងអភិវឌ្ឍន៍ស្ទែមមួយចំនួន ដូចជាៈ មជ្ឈមណ្ឌលស្រាវជ្រាវស្ទែម, មជ្ឈមណ្ឌលស្រាវជ្រាវ និងបង្កើតថ្មី, ការអភិវឌ្ឍកម្មវិធីសិក្សាស្ទែម, ការបង្កើតវប្បធម៌ស្រាវជ្រាវ និងចេញផ្សាយទាក់ទងនឹងស្ទែម, និងទំនើបភាវូបនីយកម្មបន្ទប់/ ទីពិសោធន៍។










**បន្ទប់/ទីពិសោធន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

## *វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(វ.ប.ក.)*

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានជំនាញឯកទេស/ឈានមុខក្នុងការបណ្តុះបណ្តាលមុខជំនាញវិស្វកម្ម។ រហូតមកទល់ពេលនេះមាននិស្សិតដែលបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចំនួន ៩០ ភាគរយ មានការងារធ្វើ, ចំនួន ៥ ភាគរយ បន្តការសិក្សា និងចំនួន ៥ ភាគរយទៀត បើកប្រកបអាជីវកម្មដោយខ្លួនឯង។ វ.ប.ក. បានបង្កើតសាលាថ្នាក់បណ្ឌិត នៅឆ្នាំ២០១៧ និងបានដឹកនាំសកម្មភាពស្រាវជ្រាវក្នុងនាមជាសាស្ត្រាចារ្យ/គ្រូសហណែនាំ/ប្រឹក្សាសម្រាប់សញ្ញាបត្រវិស្វកម្ម ឬសញ្ញាបត្រទ្វេ(ចេញសញ្ញាបត្ររួមគ្នា) ជាមួយសាកលវិទ្យាល័យមួយចំនួន នៅប្រទេសបារាំង និងប្រទេសបែលហ្ស៊ិក តាំងពីឆ្នាំ២០១៥។ វ.ប.ក. បានបង្កើតសាលានៅសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ដោយជ្រើស

រើសបាននិស្សិតចូលសិក្សាចំនួន ៥៣នាក់។ វ.ប.ក. បានកសាងមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍ និងមជ្ឈមណ្ឌលពហុមេឌា/ពហុមធ្យោបាយផ្សព្វផ្សាយ និងទំនាក់ទំនង ដែលផ្តល់និងគាំទ្រដល់ការសិក្សាពីចម្ងាយ(distance learning), ការសិក្សាតាមរបៀបបញ្ចូលគ្នាដែលក្នុងនោះមានការសិក្សាក្នុងថ្នាក់រួមជាមួយនឹងការប្រើបច្ចេកវិទ្យាផ្សេងៗ និងការសិក្សាតាមអ៊ីនធឺណិត (blended learning),ការសិក្សាតាមបណ្តាញ អ៊ីនធឺណិត (online learning)...











## ២.៤ ធនធាន និងការស្រាវជ្រាវស្នែម

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក.) បានធ្វើការស្រាវជ្រាវទ្រង់ទ្រាយ/ខ្នាតធំរយៈពេលប្រាំឆ្នាំ "បឹងទន្លេសាប SATREPS" និងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រដទៃៗទៀតជាច្រើនជាមួយសាកលវិទ្យាល័យ និងអង្គការ/ស្ថាប័នអន្តរជាតិនានា។ វ.ប.ក.បានផ្តល់មូលនិធិ/ថវិកាឧបត្ថម្ភដល់គ្រូ/សាស្ត្រាចារ្យធ្វើការស្រាវជ្រាវលើជំនាញវិស្វកម្ម (៥១គម្រោងស្រាវជ្រាវ នៅឆ្នាំ២០១៧)។

គម្រោងស្រាវជ្រាវធំៗដែលកំពុងដំណើរការ មានដូចជា ៖ ការរៀបចំគម្រោងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យកម្ពុជាសម្រាប់លើកកម្ពស់ការគ្រប់គ្រងទឹក និងការប្រែប្រួលអាកាសធាតុ សម្រាប់ការធ្វើកសិកម្មដំណាំស្រូវ, គម្រោងជួសជុល និងកែលម្អរចនាសម្ព័ន្ធបេតុង ដោយប្រើហ្វីប្រ៊ឹម(Fibrum),គម្រោងស្តីពីប្រេងចម្រាញ់ចេញពីរុក្ខជាតិ និងប្រេងចម្រាញ់ពីបន្លែ និងជីវៈចម្រុះ ដែលផលប្រយោជន៍ក្នុងវិស័យឧស្សាហកម្មឱសថ គ្រឿងសម្អាង អាហារូបត្ថម្ភ និងចំណីអាហារកសិកម្ម, គម្រោងស្រាវជ្រាវស្តីពីវិធីសាស្ត្រជំរុញទឹកចិត្ត ទាញការចាប់អារម្មណ៍ និងមានចីរភាព សម្រាប់អភិវឌ្ឍស្នែមនៅកម្ពុជា។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតកម្មវិធីថាមពលបៃតង/ស្អាត និងដំណោះស្រាយបៃតង ដើម្បីផ្លាស់ប្តូរបរិស្ថានក្នុងសាកលវិទ្យាល័យឱ្យក្លាយជាបរិស្ថានស្រស់ស្អាត និងចម្រុះច្រើនពណ៌/បៃ។

ក្រសួងបានផ្តល់ការស្រាវជ្រាវដែលត្រូវបានផ្តល់មូលនិធិសម្រាប់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាលើប្រធានបទ៖ (១) ការបំបែក/ចម្លងខ្លួនរបស់បរាសិត Pfhrp2 / Pfhr3, Plasmodium, Smodophilic Flavonoids នៅកម្ពុជា, (២) ការសិក្សាស្តីពីការតាមដាននិងត្រួតពិនិត្យជំងឺគ្រុនផ្តាសាយបក្សីនៅកម្ពុជា និងឥទ្ធិពលនៃការគ្រប់

គ្រងមូសនៅតាមសាលារៀនស្ដីពីការរីករាលដាលនៃជំងឺគ្រុនឈាម និងបញ្ហាដទៃទៀត។

### ២.៥ សកម្មភាពស្ទែមដទៃផ្សេងៗ

ក្រសួងបានជំរុញឱ្យបង្កើតក្លិបសិក្សាគណិតវិទ្យា ក្លិបសិក្សាគណិតវិទ្យា និងក្លិបសិក្សាវិទ្យាសាស្ត្រ នៅតាមវិទ្យាល័យចំនួន៣៦ ក្នុងរាជធានីភ្នំពេញ និងបានលើកទឹកចិត្តគ្រូបង្រៀនឱ្យបង្កើតក្លិបសិក្សាឱ្យបង្កើតក្លិបសិក្សានៅតាមសាលារៀនរបស់ខ្លួនក្នុងខេត្តព្រៃវែង។

ក្រសួងបានសហការជាមួយអង្គការស្ទែមកម្ពុជាដឹកនាំការរៀបចំពិព័រណ៍វិទ្យាសាស្ត្រ និងផ្សព្វផ្សាយការអប់រំវិទ្យាសាស្ត្រដល់សិស្សានុសិស្ស ទូទាំងប្រទេស តាមរយៈកម្មវិធីរថយន្តស្ទែម។

ក្រសួងបានសហការជាមួយអង្គការស្ទែមកម្ពុជារៀបចំមហោស្រពវិទ្យាសាស្ត្រ និងវិស្វកម្មកម្ពុជាលើកទី៣ ដែលបានប្រព្រឹត្តទៅនៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានី នាថ្ងៃទី០៩-១១ ខែមីនា ឆ្នាំ២០១៧។

សេវាអ៊ីនធឺណិតកំពុងត្រូវបានផ្ដល់ឱ្យអង្គភាព/ស្ថាប័នថ្នាក់ជាតិ, មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត, ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ, ព្រមទាំងគ្រឹះស្ថានសិក្សានានា ដោយមានទីតាំងសរុបចំនួន ៣២០ ក្រោមការផ្ដល់ការគាំទ្រពីក្រុមហ៊ុន Viettelកម្ពុជាភីធីអ៊ី., អិលធីឌី(មិត្តហ្វូន(Metfone))។













### ២.៦ ការអភិវឌ្ឍសមត្ថភាពក្នុងការអប់រំស្ទែម

#### ២.៦.១ ចំនួនសិស្សមធ្យមសិក្សាក្នុងក្រុមជម្រើសវិទ្យាសាស្ត្រ

ការប្រឡងជ្រើសរើសសិស្សពូកែមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និងអក្សរសាស្ត្រខ្មែរ ត្រូវបានរៀបចំឡើងនៅខេត្តបាត់ដំបង ដោយមានបេក្ខជនប្រឡងចំនួន ៤៨០នាក់ ក្នុងនោះមានសិស្សស្រី ២០៤ (ថ្នាក់ទី៩ និងថ្នាក់ទី១២)។ សិស្សពូកែគណិតវិទ្យា ១០នាក់ និងសិស្សពូកែរូបវិទ្យា ១០នាក់ (ស្រី ៤នាក់) ត្រូវបានបណ្តុះបណ្តាលដើម្បីចូលរួមការប្រកួតប្រជែងអូឡាំព្យាដអន្តរជាតិ ហើយក្នុងនោះក៏មានសិស្សពូកែចំនួន ៦នាក់ផងដែរបានចូលរួមការប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេង អាស៊ាន បូក ៣ លើកទី៦ នៅប្រទេសវៀតណាម។

#### ២.៦.២ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិត្រូវបានរៀបចំឡើងនៅថ្ងៃទី២១-២២ ខែសីហា ឆ្នាំ២០១៧ ដោយមានបេក្ខជនបានចុះឈ្មោះចូលប្រឡងចំនួន ១០១ ៤១៣នាក់។ មានបេក្ខជនប្រឡងជាប់ចំនួន ៦៣ ៦៦៨នាក់ ស្មើនឹង ៦៣,៨ ភាគរយ នៃបេក្ខជនដែលបានមកប្រឡងចំនួន ៩៩ ៧២៨នាក់។ក្នុងក្រុមជម្រើសផ្នែកវិទ្យាសាស្ត្រ មានបេក្ខជនប្រឡងជាប់ចំនួន ៣៤ ២៣៤ ស្មើនឹង៥៣,៤០ ភាគរយ នៃបេក្ខជនដែលបានមកប្រឡងចំនួន ៦៤ ១០៣នាក់។

#### ២.៦.៣ ចំនួនសិស្សក្នុងផ្នែកអប់រំបច្ចេកទេស

នៅឆ្នាំ២០១៧ មានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ចំនួន ៩ ស្ថិតនៅក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន ៨ ដោយមានសិស្សសរុបចំនួន ១ ៤៦៩។

#### ២.៦.៤ ការជ្រើសរើសសិក្សាមុខជំនាញស្ទែមនៅឧត្តមសិក្សា

ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មាននិស្សិតថ្នាក់បរិញ្ញាបត្ររង ចំនួន ២០ ៥៧០នាក់ ក្នុងនោះមានស្រី ៥១,០៦ ភាគរយ, និងនិស្សិតថ្នាក់បរិញ្ញាបត្រ ចំនួន ១៦៥ ៣៥៩ ក្នុងនោះមានស្រី ៤៧,៨៧ ភាគរយ។ និស្សិតដែលសិក្សាមុខជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា មានចំនួនសរុប ៤៤ ៣៦៦ ក្នុងនោះមានស្រី ២៩,៨ ភាគរយ។ និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ មានចំនួន ២១,៤៩៤ (ស្រី ២១,២៤ ភាគរយ) ដែលក្នុងនោះមាន៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ២០,២៧២នាក់ (ស្រី ២២,២ ភាគរយ) និងនិស្សិតថ្នាក់បណ្ឌិត ចំនួន ១ ២២២នាក់ (ស្រី ៥,១៦ ភាគរយ)។

#### ២.៦.៥ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន/គ្រូឧទ្ទេស

បុគ្គលិកអប់រំ នៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងគ្រូឧទ្ទេស នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ (១៤នាក់ ក្នុងនោះមានស្រី ៥) បានរៀបចំសៀវភៅស្ទែម សម្រាប់បណ្តុះបណ្តាល ការបង្រៀន និងការរៀននៅ អនុវិទ្យាល័យ ត្រពាំងច្រេស ក្នុងខេត្តរតនគិរី ក្រោមកិច្ចសហប្រតិបត្តិការជាមួយ អង្គការមូលនិធិការ៉ាម៉ានីកូ ប្រទេសកម្ពុជា។

គ្រូឧទ្ទេស និងគ្រូបង្រៀន ចំនួន ៥១នាក់(ស្រី ១៥នាក់) ត្រូវបានបណ្តុះបណ្តាលអំពីរបៀបប្រើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងការបង្រៀន និងការរៀន។ សៀវភៅគ្រូមុខវិជ្ជាគណិតវិទ្យា និង វិទ្យាសាស្ត្រ

ចំនួន ២០ ៩៦៨ ត្រូវបានបោះពុម្ព។ គ្រូបង្រៀននៅកម្រិតមូលដ្ឋាន ចំនួន ១ ១៣៨នាក់ (ស្រី ៥២៣) ត្រូវបានបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់សៀវភៅគ្រូទាំងនេះ។

គ្រូបង្រៀនចំនួន ១១១ ពីគ្រប់វិទ្យាល័យធនធាន ទាំងអស់ ទូទាំងប្រទេសទទួលបានការបណ្តុះបណ្តាល ស្តីពីវិធី សាស្ត្របង្រៀន សៀវភៅសិក្សាគោលស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ថ្នាក់ទី ១២ ថ្មី។

បុគ្គលិកអប់រំថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្តចំនួន ៣៧៤នាក់ទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការលើកកម្ពស់ និងពង្រឹងការបំពេញការងារគ្រប់គ្រង និងរដ្ឋបាលរបស់ខ្លួន។

គ្រូបង្រៀនកម្រិតមធ្យមសិក្សា ចំនួន ១១៨នាក់ ទទួលបានការបណ្តុះបណ្តាលទាក់ទងនឹងថាតើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អាចត្រូវបានបញ្ចូលទៅក្នុងការបង្រៀន និងការរៀន យ៉ាងដូចម្តេច ជាពិសេសថ្នាក់រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ។

សមត្ថភាពរបស់គរុសិស្ស-និស្សិត ចំនួន ៦១៧នាក់ ត្រូវបានពង្រឹង តាមរយៈការផ្សព្វផ្សាយអំពីរបៀបទាញយកឯកសារ/ខ្លឹមសារអប់រំស្វែម ដោយរួមមានឯកសារ/សម្ភារបង្រៀន វីដេអូបង្រៀន, និងឯកសារ/ខ្លឹមសារឌីជីថល/អេឡិកត្រូនិកអន្តរកម្ម ពីកំណត់ហេតុបណ្តាញធនធានអប់រំ (OER: Open Educational Resources) និងគេហទំព័រគ្រូ/មជ្ឈមណ្ឌលធនធានអប់រំអេឡិកត្រូនិក (Krou/ Teacher Portal)។

### ២.៦.៦ ការលើកកម្ពស់វិធីសាស្ត្របង្រៀនទាក់ទងនឹងស្វែម

វិធីសាស្ត្របង្រៀន/រៀនផ្អែកលើការសាកសួរ ស្រាវជ្រាវ ស្វែងរក (IBL: Inquiry Based Learning) ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន។ ពិសោធន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) ក៏ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន ផងដែរ។ គ្រូឧទ្ទេសថ្នាក់ជាតិ និងមន្ត្រីបច្ចេកទេស ចំនួន ២៨ នាក់ (ស្រី ៤) ត្រូវបានបណ្តុះបណ្តាលលើវិធីសាស្ត្របង្រៀនដែលទាក់ទងនឹងស្វែម ដោយគាំទ្រដោយ អង្គការវីវីអូប៊ីកម្ពុជា (VVOB Cambodia)។

## ២.៧ គម្រោងកម្ចីប្រាក់សម្រាប់សិស្សពូកែ/ស្វែម

គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP)៖ ការផ្តល់អាហារូបករណ៍ដល់សិស្សពូកែក្នុងក្រុមជម្រើសផ្នែកវិទ្យាសាស្ត្រ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ, សិស្សពូកែកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងក្រុមជម្រើសផ្នែកវិទ្យាសាស្ត្រ ចំនួន ១ ៥០០នាក់ នឹងត្រូវបានផ្តល់អាហារូបករណ៍។ ពួកគេនឹងត្រូវជ្រើសរើស ដោយផ្អែកលើលក្ខណវិនិច្ឆ័យដែលថា ៦០ ភាគរយនៃអ្នកទទួលបានអាហារូបករណ៍ជាសិស្សស្រី។អាហារូបករណ៍នេះ ត្រូវបានរំពឹងថានឹងលើកទឹកចិត្តសិស្សពូកែដែលគួរលើកសរសើរ ដោយរួមទាំងសិស្សទាំងឡាយណា ដែលមកពីគ្រួសារក្រីក្រ ដើម្បីបន្ត និងបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រមទាំងពង្រីក និងបង្កើនចំនួនសិស្ស-និស្សិតដែលកាន់តែមានគុណសម្បត្តិល្អ ចូលរៀន និងចាប់យកមុខជំនាញស្វែមនៅកម្រិតឧត្តមសិក្សា។

### ២.៨ ចំនួនមេដាយបានពីការប្រកួតប្រជែងស្វែម

- សិស្សពូកែចំនួន ៦នាក់ ក្នុងនោះមានស្រី ៣នាក់ បានចូលរួមការប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអាស៊ាន បូក៣ លើកទី៦ នៅប្រទេសវៀតណាម ហើយទទួលបានមេដាយកិត្តិយសចំនួន ១៤ ៖ មេដាយមាស ១, មេដាយប្រាក់ ១០, និងមេដាយសំរឹទ្ធ ៣។
- សិស្សពូកែផ្នែករូបវិទ្យាចំនួន ៥នាក់ ក្នុងនោះមានស្រី ៣នាក់ បានចូលរួមការប្រកួតប្រជែងការប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដអន្តរជាតិ នៅប្រទេសឥណ្ឌូនេស៊ី ហើយទទួលបានរង្វាន់កិត្តិយសចំនួន ៤។
- សិស្ស ៤នាក់ (ស្រី ១)បានចូលរួមកម្មវិធី SSYS Program ហើយសិស្ស ១២នាក់ (ស្រី ៣នាក់) បានចូលរួមកម្មវិធីប្រកួតប្រជែងអូឡាំព្យាដវិទ្យាសាស្ត្រវ័យក្មេងអន្តរជាតិ (IJSO: International Junior Science Olympiad )ដោយទទួលបានមេដាយសំរឹទ្ធ ១។

### ២.៩ ការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំស្វែម

#### ២.៩.១ គោលនយោបាយ/អន្តរាគមន៍ដើម្បីជំរុញសិស្ស-និស្សិតស្រីឱ្យបន្តការសិក្សា/អប់រំស្វែម

ស្ត្រីកំពុងចូលរួមជំរុញការអប់រំបច្ចេកវិទ្យា និងសហគ្រិនភាព តាមរយៈកម្មវិធីប្រកួតប្រជែងតិចណូវេសិន (Technovation)។ ស្ត្រីវ័យក្មេងដែលមានអាយុចន្លោះពី១៣ ទៅ ១៦ឆ្នាំ ត្រូវបានផ្តល់ឱ្យនូវកម្មវិធីបណ្តុះបណ្តាលការសរសេរកូដកុំព្យូទ័រ(ភាសាកុំព្យូទ័រ), និងបង្កើតកម្មវិធីកុំព្យូទ័រគំរូដំបូង និងកម្មវិធីទូរស័ព្ទ ដែលអាចដោះស្រាយបញ្ហាសង្គម ជារៀងរាល់សប្តាហ៍ ក្នុងអំឡុងពេល ១២សប្តាហ៍។ រៀងរាល់ឆ្នាំ ក្រុមដែលល្អបំផុតដែលត្រូវបានជ្រើសរើសចេញពីការប្រកួតថ្នាក់ជាតិ នឹងត្រូវបានអញ្ជើញឱ្យចូលរួមការប្រកួតប្រជែងអន្តរជាតិ/សាកល ដែលរៀបចំប្រព្រឹត្តទៅនៅសហរដ្ឋអាមេរិក។ គម្រោងនេះ ត្រូវបានអនុវត្តក្រោមកិច្ចសហប្រតិបត្តិការជាមួយគម្រោងនវានុវត្តន៍អភិវឌ្ឍន៍ (Development Innovations)។

#### ២.៩.២ អាហារូបករណ៍

មានសិស្សស្រី ចំនួន ៧៩៧ ទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររង ហើយសិស្ស ចំនួន ១២ ១៧០ ទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ។

#### ២.៩.៣ អន្តេវាសិកដ្ឋាន

ក្រសួងបានបង្កើនចំនួនអាហារូបករណ៍សម្រាប់សិស្ស-និស្សិតស្រី តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភធនកម្ចី/ឥណទានសម្រាប់សិស្ស-និស្សិតស្រី និងការសាងសង់អន្តេវាសិកដ្ឋាន ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានអន្តេវាសិកដ្ឋានចំនួន ៣០ ដែលអាចផ្តល់កន្លែងស្នាក់នៅសម្រាប់សិស្ស-និស្សិតចំនួន ៣ ៧៨៨នាក់ ក្នុងនោះមានសិស្ស-និស្សិតស្រី ចំនួន ១,០៩៦នាក់។

### ២.១០ លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

#### ២.១០.១អង្គការយូណេស្កូប្រចាំនៅកម្ពុជា(UNESCOCambodia)

អង្គការយូណេស្កូប្រចាំនៅកម្ពុជាគាំទ្រការជំរុញ និងលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ និងការចេះ និងការយល់ដឹងអំពីវិទ្យាសាស្ត្រ នៅកម្ពុជា។ អង្គការយូណេស្កូបានគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដើម្បីលើកកម្ពស់ និងអភិវឌ្ឍវិទ្យាសាស្ត្រ

បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម)។ ជាពិសេស អង្គការយូណេស្កូភ្នំពេញ គាំទ្រ និងចូលរួមក្នុងកម្មវិធីដែលទាក់ទងនឹងស្ទែមផ្សេងៗ៖ (១) មហោស្រពភាពយន្តវិទ្យាសាស្ត្រកម្ពុជា, (២) មហោស្រពវិទ្យាសាស្ត្រ និងវិស្វកម្មកម្ពុជា, (៣) មហោស្រពវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាកម្ពុជា, និង(៤) ជាទីប្រឹក្សាដល់ការរៀបចំសេចក្តីព្រាងនៃផែនការសកម្មភាព សម្រាប់គោលនយោបាយស្តីពី ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅកម្ពុជា។

### ២.១០.២ អង្គការវីអូប៊ីកម្ពុជា (VVOB Cambodia) (ឌីវីឌីអប់រំ)

អង្គការវីអូប៊ីកម្ពុជាដោយមានការគាំទ្រពីសាកលវិទ្យាល័យនៅប្រទេសបែលហ្ស៊ិក Flemish University Collegesបានបង្កើតឌីវីឌីមេរៀនគណិតវិទ្យា និងស្ទែម សម្រាប់បឋមសិក្សា។ ឌីវីឌីអប់រំនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងសម្ភារបណ្តុះបណ្តាលរបស់អង្គការវីអូប៊ីកម្ពុជា សម្រាប់បណ្តុះបណ្តាលគ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យ និងវិក្រឹតការ និងគ្រូបង្រៀននៅសាលារៀនអនុវត្តន៍នានា ដើម្បីជួយឱ្យគ្រូឧទ្ទេស និងគ្រូបង្រៀនទាំងអស់អាចប្រើប្រាស់ចំណេះដឹង និងជំនាញទាំងនេះ សម្រាប់បណ្តុះបណ្តាល និងគាំទ្រដល់គរុសិស្សនិងសិស្ស។

អង្គការវីអូប៊ីកម្ពុជា នឹងរៀបចំបង្កើតវីស៊ីឌីមេរៀនស្ទែមបន្ថែមទៀត នៅក្នុងឆ្នាំ២០១៨។

### ២.១០.៣ឃីត ស៊ីធី (Kids City)

កម្មវិធីវិទ្យាសាស្ត្រ/ស្ទែមរបស់ឃីត ស៊ីធី បាននិងកំពុងត្រូវបានអនុវត្ត ដោយមានការចូលរួមពីមន្ត្រី/បុគ្គលសំខាន់ៗចំនួន ២០០នាក់, គ្រូបង្រៀនមុខវិជ្ជាដែលទាក់ទងនឹងស្ទែមចំនួន ៤០០នាក់, និងសិស្សានុសិស្សចំនួន ២០០០នាក់ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនានាក្នុងរាជធានី ខេត្តៈ សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដើម្បីផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីការអប់រំស្ទែម។

- សាលារៀនចំនួន ៤០ ក្នុងរាជធានីភ្នំពេញ (សាលាបឋមសិក្សា ២០, អនុវិទ្យាល័យ ១០,និងវិទ្យាល័យ ១០) ដោយមានគ្រូបង្រៀនចំនួន ១០នាក់ ពីសាលារៀននីមួយៗ
- សាលារៀនចំនួន ២០ ក្នុងរាជធានីភ្នំពេញ (សាលាបឋមសិក្សា ១០, អនុវិទ្យាល័យ ៥, និងវិទ្យាល័យ ៥) ដោយមានសិស្សចំនួន ១០០នាក់ ពីសាលារៀននីមួយៗ
- ខេត្តចំនួន ២ ដោយមានបុគ្គលិកអប់រំសំខាន់ៗ ចំនួន ១០០ នាក់ពីខេត្តនីមួយៗ

### ២.១០.៤ តិចណូវេសិន (Technovation)

តិចណូវេសិន (Technovation) ជាកម្មវិធីបច្ចេកវិទ្យា និងសហគ្រិនភាពមួយ សម្រាប់ស្ត្រីវ័យក្មេងដោយផ្តោតទៅលើស្ត្រីដែលមានចន្លោះអាយុ ១០-១៨។ កម្មវិធីនេះបានជួយ ស្ត្រីវ័យក្មេងកម្ពុជា ជាង២០០នាក់ឱ្យរៀនពីរបៀបកំណត់អត្តសញ្ញាណបញ្ហានៅក្នុងសហគមន៍របស់ពួកគេនិង រៀនជំនាញកូដ(កម្មវិធី)និងអភិវឌ្ឍន៍អាជីវកម្មជាក់ស្តែង និងបង្កើតកម្មវិធីសម្រាប់ដាក់ឱ្យដំណើរការក្នុងទូរស័ព្ទ ដើម្បីដោះស្រាយបញ្ហា។ កម្មវិធីតិចណូវេសិន បានបណ្តុះបណ្តាលបុគ្គលិកជំនាញវិជ្ជាជីវៈបច្ចេកវិទ្យាព័ត៌មាន អ្នកជំនួញ/ ស្ត្រីអ្នកជំនួញ និងស្ត្រីមានជំនាញវិជ្ជាជីវៈក្នុងផ្នែកបច្ចេកវិទ្យា ឱ្យក្លាយជាគ្រូបង្វឹក/បង្រៀនបច្ចេកទេស និងអាជីវកម្ម បានចំនួនជាង ១០០នាក់។






### ២.១០.៥ សៀវភៅព័ត៌មានដៃគូ និងអង្គភាព/ស្ថាប័នស្ទែម នៅកម្ពុជា

សៀវភៅព័ត៌មានដៃគូ និងអង្គភាព/ស្ថាប័នស្ទែម នៅកម្ពុជា របស់ក្រុមការងារស្ទែម នៃក្រសួងអប់រំ យុវជន និង កីឡា ជាការប្រមូលផ្តុំនៃស្ថាប័ន/អង្គភាពនានា ដែលកំពុងធ្វើការទាក់ទងនឹងការអប់រំស្ទែម នៅកម្ពុជា។អង្គភាព /ស្ថាប័នជាសមាជិកនៃក្រុមការងារស្ទែម មានភាពចម្រុះផ្សេងៗគ្នា ដោយសារតែមានចំនួនអង្គភាព/ ស្ថាប័នជាច្រើននៅក្នុងនោះ។ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈស្ថាប័ន/អង្គភាពផ្តល់ជំនួយអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងស្ថាប័នរដ្ឋាភិបាល ដែលកំពុងធ្វើការទាក់ទងនឹងការអប់រំស្ទែម ក្នុងក្តីសង្ឃឹម និងរំពឹងថានឹងអាចផ្តល់ឱ្យសិស្ស/និស្សិតកម្ពុជានូវការអប់រំដែលមានស្តង់ដាកាន់តែខ្ពស់។

រូបភាព ៤.១៖ តារាងបង្ហាញអង្គភាព/ស្ថាប័នស្ទែមក្នុងសៀវភៅព័ត៌មានដៃគូនិងអង្គភាព/ស្ថាប័នស្ទែម ដែលត្រូវបានចាត់ថ្នាក់តាមប្រភេទនៃអង្គភាព/ស្ថាប័ន

| អង្គភាព/ស្ថាប័ន | អ្នកអនុវត្ត | អ្នកផ្តល់ជំនួយ | ទាំងពីរ | CSR |
|---|---|---|---|---|
| អង្គការបណ្ឌិត្យសភាវិស្វកម្មនិងបច្ចេកវិទ្យាអាស៊ាន-កម្ពុជា (ASEAN Academy of Engineering and Technology-Cambodia) | X | | | X |
| គណៈកម្មការអប់រំរបស់សភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា (AmCham Education Committee) | | | | X |
| ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា (Australian Embassy in Cambodia) | | X | | |
| ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅកម្ពុជា British Embassy in Cambodia | | X | | |
| អង្គការមូលនិធិគ្រាស់កុមារកម្ពុជា | X | | | |
| សហគមន៍អ្នកគណិតវិទ្យាកម្ពុជា | X | | | |
| មូលនិធិការ៉ាម៉ានីកូ ប្រទេសកម្ពុជា | X | | | |
| CCF Neeson Cripps Academy(មូលនិធិកុមារកម្ពុជា) | X | | | |
| គម្រោងនវានុវត្តន៍អភិវឌ្ឍន៍(Development Innovations) | | | X | |
| អង្គការ e2STEMEducation | X | | | |
| សាលាអន្តរជាតិ អេច ខេ ស៊ី ទ្រី (HKC Tree International School) | X | | | |
| កម្មវិធីអភិវឌ្ឍន៍អន្តរជាតិ នៅកម្ពុជា (IDPEducation) | X | | | |
| មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈIT Step Academy | | | X | |
| ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន នៅកម្ពុជា (JICA) | | | X | |
| អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) | | | X | |
|ឃីត ស៊ីធី អាស៊ី (Kids City Asia) | X | | | X |
| ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ នៅកម្ពុជា (KOICA) | | | X | |
| មជ្ឈមណ្ឌលក្រមង៉ុយ (Le Centre KramNgoy) | X | | | |
| វិទ្យាស្ថានបើកទូលាយ (Open Institute) | X | | | |
| អង្គការស្ទែមកម្ពុជា (STEM Cambodia Organization) | | | X | |
| អង្គការអប់រំស្ទែមសម្រាប់កម្ពុជា (STEM Education Organization for Cambodia) | | | X | |
| មជ្ឈមណ្ឌល Cambodia STEM Hub | X | | | |
| ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID:United States Agency for International Development) | | | X | |

# សកម្មភាពជំរុញការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)















